**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលក្រុងប៉ៃលិន**
**គណៈកម្មាធិការលទ្ធកម្ម**

លេខ : ៤៤៣/១៦ សជណ.កបល.

# សេចក្ដីជូនដំណឹង

**ស្ដីពី**

**ការអញ្ជើញចូលរួមពិគ្រោះថ្លៃការងារសាងសង់របង ខ្លោងទ្វារ និងស្លាកសញ្ញាសាលាក្រុង**

សាលាក្រុងប៉ៃលិន សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា សាលាក្រុងប៉ៃលិន នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារសាងសង់ **របង ខ្លោងទ្វារ និង ស្លាកសញ្ញាសាលាក្រុង**។

សាលាក្រុងប៉ៃលិន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ។ ឯកសារពិគ្រោះថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មក្រុងប៉ៃលិន ដែលមានអាសយដ្ឋាននៅសាលាក្រុងប៉ៃលិន ចាប់ពីថ្ងៃទី **៣០** ខែ **សីហា** ឆ្នាំ **២០១៦** តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ 016 666 124 , 097 555 6877) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ វេលាម៉ោង ៩ និង ៣០ នាទីព្រឹក។

ការបើកសំណើពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

ប៉ៃលិន ថ្ងៃទី ៣០..... ខែ សីហា ឆ្នាំ ២០១៦
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ស៊ុន ឃី

**ចម្លងជូន ៖**
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តប៉ៃលិន
-ក្រុមប្រឹក្សាក្រុងប៉ៃលិន
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ។